**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការធ្វើយុទ្ធនាការអប់រំសុខភាព ដើម្បីរួមគ្នាទប់ស្កាត់ និងបង្ការការចម្លងវីរុសកូវីដ-១៩ ជាពិសេស ពពួកបំប្លែងថ្មី អូមីក្រុង (Omicron) នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ទីតាំងនៅខេត្តកំពង់ស្ពឺ

---

យោងតាមសារាចរររបស់រាជរដ្ឋាភិបាល លេខ ០២ សរ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ចុះហត្ថលេខាដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ស្តីពីការពង្រឹងការអនុវត្តវិធានការប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលក្នុងសហគមន៍នៃវីរុសកូវីដ-១៩ បំប្លែងថ្មីប្រភេទ "អូមីក្រុង" សំដៅទប់ស្កាត់ការឆ្លងរាលដាលជំងឺកូវីដ-១៩ និងដោយសង្កេតឃើញថា បច្ចុប្បន្ននេះ ស្ថានភាពនៃការឆ្លងវីរុសកូវីដ-១៩ ជាពិសេសអូមីក្រុង នៅក្នុងព្រះរាជាណាចក្រកម្ពុជា គួរឱ្យមានការព្រួយបារម្ភ ដោយយើងនៅតែមានរកឃើញអ្នកវិជ្ជមានវីរុសកូវីដ-១៩ ស្ថិតនៅខ្ពង់រយជារៀងរាល់ថ្ងៃ និងមានករណីស្លាប់បាត់បង់ជីវិតជាបន្តបន្ទាប់ផងដែរនោះ ហើយតាមការសង្កេតរបស់ក្រសួងសុខាភិបាលឃើញថា បងប្អូនប្រជាពលរដ្ឋយើងមួយចំនួនមិនបានបន្តយកចិត្តទុកដាក់អនុវត្ត ឬក៏អនុវត្តមិនបានត្រឹមត្រូវ មិនបានហ្មត់ចត់ និងម៉ឺងម៉ាត់ នូវវិធានការការពារការចម្លងជំងឺកូវីដ-១៩ ជាពិសេសការជួបជុំគ្នានៅតាមពិធីផ្សេងៗមានការខ្វះខាត ឬមិនមានការប្រតិបត្តិត្រឹមត្រូវតាមវិធានការសុខាភិបាល ដែលជាហានិភ័យខ្ពស់នៃការចម្លងវីរុសកូវីដ-១៩ ក្រសួងសុខាភិបាល សូមជម្រាបជូនបងប្អូនសាធារណជនទាំងអស់ឱ្យបានជ្រាបថា៖ ក្រសួងសុខាភិបាល តាមរយៈអនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ (អ.ប.ទ) នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ នឹងរៀបចំបន្តធ្វើយុទ្ធនាការជាតិអប់រំការពារការចម្លងវីរុសកូវីដ-១៩ ក្រោមប្រធានបទ ***"កូវីដ-១៩ បំប្លែងថ្មី អូមីក្រុង ឆ្លងខ្លាំងជាងមុន អាចបណ្តាលឱ្យមានហានិភ័យដល់អ្នក និងគ្រួសារ"*** ដើម្បីជំរុញការទទួលខុសត្រូវរបស់បុគ្គល គ្រួសារ សហគមន៍ និងស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន រួមគ្នាទទួលខុសត្រូវក្នុងស្មារតីសាមគ្គីភាព ដើម្បីកាត់ផ្តាច់ខ្សែចម្លងវីរុសកូវីដ-១៩ បំប្លែងថ្មី ឱ្យមាននិរន្តរភាពនៃការរស់នៅជាមួយនឹងវីរុសកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីផងដែរ។

បច្ចុប្បន្ននេះ វីរុសកូវីដ-១៩ ប្រភេទអូមីក្រុង (Omicron) គឺកំពុងតែសកម្មចរាចរយ៉ាងឆាប់រហ័សដោយគ្មានព្រំដែន និងគ្មានលិខិតឆ្លងដែន នៅលើសកលលោក នៅក្នុងតំបន់ និងនៅក្នុងប្រទេសកម្ពុជា ដែលតម្រូវឱ្យបងប្អូនចាំបាច់ត្រូវតែប្រុងប្រយ័ត្ន និងបន្តចូលរួមការពារ ព្រមទាំងឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ នេះ



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

ឱ្យបានទាន់ពេលវេលា ដើម្បីជៀសវាងបាននូវមហន្តរាយសុខភាពសាធារណៈ ផលប៉ះពាល់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចសង្គម រួមទាំងការចៀសវាងបាននូវការវិលត្រឡប់ទៅរកផលលំបាកនៃការរស់នៅប្រចាំថ្ងៃរបស់បងប្អូន ដើម្បីធានាបាននូវនិរន្តរភាពនៃការរស់នៅធម្មតាក្នុងប្រក្រតីភាពថ្មីរបស់បងប្អូនបានយូរអង្វែង ផងដែរ។ សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ខិតខំបន្តអនុវត្តន៍ឱ្យបានខ្ជាប់ខ្ជួននូវវិធានការសុខាភិបាលជាពិសេស គឺវិធានការ "**៣ការពារ និង ៣កុំ**" និងអញ្ជើញទៅ**ចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ ឬដូសជំរុញ** ឱ្យបានគ្រប់ៗគ្នា។

យុទ្ធនាការជាតិអប់រំនេះ នឹងប្រព្រឹត្តិទៅនៅខេត្តកំពង់ស្ពឺ ក្នុងក្របខណ្ឌទូទាំងប្រទេស នៅតាមបណ្តារាជធានី-ខេត្ត ផ្សេងទៀតក៏មានការណែនាំឱ្យចាត់ចែងរៀបចំយុទ្ធនាការនេះដែរ ហើយនឹងប្រព្រឹត្តទៅក្រោមអធិបតីភាពឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល ព្រមទាំងមានការចូលរួមពីសំណាក់លោកជំទាវវេជ្ជបណ្ឌិត ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានអនុគណៈកម្មការអប់រំ បណ្តុះបណ្តាល និងទំនាក់ទំនងសាធារណៈ នៃគណៈកម្មការអន្តរក្រសួងដើម្បីប្រយុទ្ធនឹងជំងឺកូវីដ-១៩ លោកស្រីវេជ្ជបណ្ឌិត លី អាយលែន តំណាងអង្គការសុខភាពពិភពលោក ប្រចាំនៅកម្ពុជា និងលោកស្រី ហ្វូរ៉ុក ហ្វាយូហ្សាត តំណាងអង្គការយូនីសេហ្វ ប្រចាំនៅកម្ពុជា ផងដែរ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនសាធារណជន និងអ្នកសារព័ត៌មានទាំងអស់ជ្រាបជាព័ត៌មាន និងចូលរួមផ្តិតយករូបភាពនៃយុទ្ធនាការអប់រំជាតិក្រោមប្រធានបទ "***កូវីដ-១៩ បំប្លែងថ្មីអូមីក្រុង ឆ្លងខ្លាំងជាងមុន អាចបណ្តាលឱ្យមានហានិភ័យដល់អ្នក និងគ្រួសារ***" ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ នៅខេត្តកំពង់ស្ពឺ ព្រមទាំងចូលរួមធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយផងដែរ។

សម្រាប់ព័ត៌មានបន្ថែមស្តីពីយុទ្ធនាការនេះ សូមទាក់ទងតាមរយៈទូរស័ព្ទលេខ៖ ០១២ ៩៦០ ៧២៧ ឬ ០១២ ៨៣៦ ៨៦៨ ឬ ០៩៩ ៣២៣ ៥៣៦។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២២



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩